**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០២៥៩ ព.ណ.ភ.តស.ល

ថ្ងៃសុក្រ ៨រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០២១

**ជម្រាបមក**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន ស្តេនដាត ខេប៊ល (ខេមបូឌា)**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលខ្សែភ្លើង និងខ្សែកាបអគ្គិសនីម៉ាក STANDARD CABLE របស់ក្រុមហ៊ុន **ស្តេនដាត ខេប៊ល (ខេមបូឌា)** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

- លិខិតរបស់ក្រុមហ៊ុន **ស្តេនដាត ខេប៊ល (ខេមបូឌា)** ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០២០
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Standard Cable Company Limited ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៣៨៣១១/១១ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលខ្សែភ្លើង និងខ្សែកាបអគ្គិសនីពាក់ម៉ាកខាងលើរបស់ក្រុមហ៊ុន **ស្តេនដាត ខេប៊ល (ខេមបូឌា)** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Standard Cable Company Limited ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Standard Cable Company Limited ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះ អ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

*<u>ចម្លងជូន:</u>*

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA. Phone/Facsimile: (855) 23 866 469

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
នាយកដ្ឋានកម្មសិទ្ធិបញ្ញា

STANDARD CABLE

ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
ចូល លេខ: 2801 ថ្ងៃទី: 30.12.20 ម៉ោង: 3h30

# កំណត់បង្ហាញ

**កម្មវត្ថុ** ៖ សំណើកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការនាំចូល និងចែកចាយផលិតផលខ្សែភ្លើង និងខ្សែកាបអគ្គិសនីម៉ាក របស់ក្រុមហ៊ុន **ស្តេនដាត ខេប៊ល (ខេមបូឌា)**។

**អ្នកស្នើសុំ** ៖ ក្រុមហ៊ុន **ស្តេនដាត ខេប៊ល (ខេមបូឌា)**

**ខ្លឹមសារ** ៖
☑ មានលិខិតស្នើសុំកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខ
☑ មានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីក្រុមហ៊ុនបរទេស
☑ មានឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុនក្នុងស្រុក
☑ មានឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកនេះ។

ដូច្នេះ លិខិតប្រគល់សិទ្ធិផ្តាច់មុខមានទម្រង់អាចអនុញ្ញាតឱ្យធ្វើការកត់ត្រាបាន ដោយផ្តល់រយៈពេលមានសុពលភាព៖
☑ ២ឆ្នាំ
☐ តិចជាង ២ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ដល់ថ្ងៃទី ខែ ឆ្នាំ

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គនាយក ឯកឧត្តម លោកជំទាវអនុ/រដ្ឋលេខាធិការ** និង **ឯកឧត្តមរដ្ឋមន្ត្រី**មេត្តាពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២០
**ប្រធាននាយកដ្ឋាន**

**សួន វិជ្ជា**

## យោបល់របស់ឯកឧត្តមអគ្គនាយក 16-12-20 11:00

**សូមគោរពជូន**
**ឯកឧត្តមអនុរដ្ឋលេខាធិការ**

បានពិនិត្យឃើញថា គួរអនុញ្ញាតកត់ត្រាសិទ្ធិផ្តាច់មុខនេះ
សូមគោរពជូនឯកឧត្តមមេត្តាពិនិត្យ និងសម្រេច
ដោយក្តីគោរព
21.12.20
**ម៉ុម ថារណា**

## យោបល់របស់ឯកឧត្តមអនុរដ្ឋលេខាធិការ

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋលេខាធិការ**

សូមគោរពជូនឯកឧត្តមរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច។
ដោយក្តីគោរព។
22/12/20

## យោបល់របស់ឯកឧត្តមរដ្ឋលេខាធិការ

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ឯកសារគ្រប់គ្រាន់ គួរអនុញ្ញាតជាគោលការណ៍ កត់ត្រាសិទ្ធិផ្តាច់មុខនេះ ។
សូមឯ.ឧ រដ្ឋមន្ត្រីពិនិត្យ និងសម្រេច ។
ដោយក្តីគោរព
28/12/20
**អ៊ឹក_ប្រូជា**

## សេចក្តីសម្រេចរបស់ឯកឧត្តមរដ្ឋមន្ត្រី

**ឯកភាពជាគោលការណ៍**

**ប៉ាន_សូរស័ក្តិ**
04.01.2021

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋាន សេវាពាណិជ្ជកម្ម
នាយកដ្ឋានកម្មសិទ្ធិបញ្ញា
ការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម

# កំណត់បង្ហាញ
# ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

- **កម្មវត្ថុ៖** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម៉ាក STANDARD CABLE
- **អ្នកស្នើសុំ៖ ក្រុមហ៊ុន ស្តេនដាត ខេប៊ល (ខេមបូឌា)**
- **យោង៖** គោលការណ៍ឯកភាព**ឯកឧត្តមរដ្ឋមន្ត្រី** ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០២១

ដោយមានចំណារឯកភាពឯកឧត្តមរដ្ឋមន្ត្រី គួរធ្វើការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើម៉ាក ជូន។

**ប្រធានការិយាល័យក្រោយចុះបញ្ជីម៉ាកពាណិជ្ជកម្ម**

06.01.2021

**លុយ សុផល្លា**

| **យោបល់ឯកឧត្តមអគ្គនាយក** 27-1-21 | **យោបល់អនុប្រធាននាយកដ្ឋាន** |
| --- | --- |
| **ម៉ុម ថាវីណា** 2-2-21 | **គោរពជូន**<br>យោងមាត្រា៣ និង១១ នៃច្បាប់ម៉ាក និងឯកសារតម្រូវដែលបានដាក់មកនាងខ្ញុំ/ខ្ញុំបាទយល់ឃើញថា ក្រសួងអាចអនុញ្ញាតឲ្យធ្វើការ កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន តាមការស្នើសុំ ។<br>សូមលោកប្រធាន ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច តាមការ គួរ។<br>06.01.21 |
| **យោបល់របស់ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ** | **យោបល់ប្រធាននាយកដ្ឋាន** |
| **រដ្ឋលេខាធិការ**<br>3/2/21<br>**អ៊ឹក_ប្រជា** | **យោងគោលការណ៍ឯកភាពរបស់ ឯកឧត្តមរដ្ឋមន្ត្រី៖** ...............<br>សូម ឯកឧត្តមអគ្គនាយក ឯកឧត្តម/លោកជំទាវ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ មេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ។<br>27 JAN 2021<br>**ស្ងួន_វិជ្ជា** |